# ការរក្សាការពារ ក្នុងរឿងក្ដីរដ្ឋប្បវេណី ផ្នែក 5

ថ្ងៃទី 25 ខែមេសា ឆ្នាំ2018
ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

# ការអនុវត្តរក្សាការពារ

# លក្ខខណ្ឌនៃការអនុវត្តរក្សាការពារ

- ផ្អែកលើឯកសារចម្លងឃថាភូតនៃដីកាសម្រេចរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា562 កថា.ទី1)

  ⇒មិនចាំបាច់មានរូបមន្តអនុវត្ត។ ប៉ុន្តែ បើសិនជាជនក្រៅពីភាគីនៃដីកាសម្រេចរក្សាការពារក្លាយជាភាគីនៃការអនុវត្ត ចាំបាច់ត្រូវមានរូបមន្តអនុវត្ត(កថាខណ្ឌដដែល វាក្យ.ទី2)។

- ចាំបាច់ត្រូវអនុវត្តនៅក្នុងអំឡុងពេល 2សប្តាហ៍ គិតចាប់ពីពេលបញ្ជូនដីកាសម្រេចរក្សាការពារទៅម្ចាស់បំណុល(មាត្រាដដែល កថា.ទី2)។ ប៉ុន្តែ នៅប្រទេសជប៉ុន មានទស្សនៈដែលមានប្រៀបមួយបានលើកឡើងថា ក្នុងករណីនៃការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់មិនឲ្យធ្វើសកម្មភាពវិញនោះ ពុំមាននូវការអនុវត្តអំពីការកម្រិតអំឡុងពេលទេ។
- មិនទាមទារនូវការបញ្ជូនដីកាសម្រេចរក្សាការពារទៅកូនបំណុលជាមុនទេ(មាត្រាដដែល កថា.ទី3)។

# ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

1. សមត្ថកិច្ច

តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា567 កថា.ទី2)

2. វិធីសាស្ត្រ

ចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន (មាត្រាដដែល កថា.ទី3 និង ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា32)។ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់អំពីការចុះបញ្ជី (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា567 កថា.ទី4 និង ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា16) ។ អានុភាពនៃការអនុវត្ត នឹងកើតមានឡើងនៅក្រោយពេលចុះបញ្ជី (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា567 កថា.ទី4 មិនអនុវត្តដូចគ្នានូវមាត្រា421 កថា.ទី2 នៃច្បាប់ដដែលទេ)។

# ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

3. ការដាស់តឿនឲ្យធ្វើសេចក្តីថ្លែងការណ៍

ដោយសារតែតុលាការមិនដឹងថា ម្ចាស់បំណុលមាន ឬ គ្មានសិទ្ធិលើបំណុល ឬ ចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសទេ ដូច្នេះ នៅប្រទេសជប៉ុន  ក្នុងករណីដែលមានការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ជាធម្មតា តុលាការជម្រុញឲ្យម្ចាស់បំណុលដាក់ពាក្យសុំដាស់តឿនឲ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 566 និងមាត្រា405)

# ការអនុវត្តវិបអ្វូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

1. សមត្ថកិច្ច

អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា565 កថា.ទី1 )

2. វិធីសាស្ត្រ

អាជ្ញាសាលាកាន់កាប់វត្ថុដែលជាកម្មវត្ថុ (ក្នុងករណីវត្ថុដែលជាកម្មវត្ថុគឺជាសាច់ប្រាក់ ត្រូវផ្ញើនៅតុលាការដែលអាជ្ញាសាលានោះស្ថិតនៅ។ ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា565 កថា.ទី1 និង កថា.ទី2)។ ក្នុងករណីវត្ថុដែលជាកម្មវត្ថុមិនត្រូវបានកំណត់ទេ អាជ្ញាសាលានឹងជ្រើសរើសវត្ថុដែលជាកម្មវត្ថុ (យោងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា565 កថា.ទី4 និង មាត្រា385 កថា.ទី3)។ ហើយក៏អាចអនុវត្តចំពោះចលនវត្ថុដែលម្ចាស់បំណុលកាន់កាប់ ឬ ចលនវត្ថុដែលតតិយជនកាន់កាប់ ហើយអ្នកកាន់កាប់នោះមិនបដិសេធអំពីការប្រគល់ ដែលមាននៅទីកន្លែងនោះបាន (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 565 កថា.ទី4 និង មាត្រា386)។

# ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

3. ចំណុចប្រុងប្រយ័ត្ន

- ក្នុងករណីរថយន្ត ឬ ម៉ូតូ ដែលបានចុះបញ្ជីជាអាទិ៍ អាជ្ញាសាលាត្រូវផ្ទុកផ្ដាក់អំពីការចុះបញ្ជី (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា565 កថា.ទី4 និង មាត្រា387 កថា.ទី1)។
- ក្នុងករណីដែលមានពាក្យសុំឲ្យអនុវត្តមានចំនួនច្រើនលើទីកន្លែងដដែលនោះ ចាំបាច់ត្រូវរួមបញ្ចូលពាក្យសុំទាំងនោះ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា565 កថា.ទី4 និង មាត្រា388 កថា.ទី1)។
- ហាមឃាត់ចំពោះ ការរឹបអូសជាបណ្ដោះអាសន្នដែលហួសប្រមាណ ឬ ការអនុវត្តក្នុងករណីដែលតម្លៃនៃចលនវត្ថុមិនគ្រប់គ្រាន់នឹងសោហ៊ុយសម្រាប់នីតិវិធី (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា565 កថា.ទី4 មាត្រា391 និង មាត្រា392)។
- បើសិនជាមានការព្រួយបារម្ភណ៍ថាចលនវត្ថុដែលត្រូវបានអនុវត្តនឹងចុះតម្លៃយ៉ាងខ្លាំងជាអាទិ៍ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះបាន ហើយអាចផ្ញើប្រាក់ដែលបានពីការលក់នៅតុលាការដែលខ្លួនស្ថិតនៅ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 565 កថា.ទី3)។

# ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

1. សមត្ថកិច្ច (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា568 កថា.ទី1)

- នៅពេលដែលអនុវត្តតាមវិធីសាស្ត្រទី ① គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន
- នៅពេលដែលអនុវត្តតាមវិធីសាស្ត្រទី ② គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ

2. វិធីសាស្ត្រ (មាត្រាដដែល កថា.ទី2)

①របៀបចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន (ក្រឡាបញ្ជីផ្ទុកផ្ដាក់ (មាត្រាដដែលកថា.ទី3)

②របៀបដែលបង្គាប់ឲ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវាជាអាទិ៍ ហើយឲ្យផ្ដល់លិខិតនោះទៅតុលាការ។

# ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

- ការអនុវត្តនូវការចាត់ចែងជាបណ្ដោះ ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬ វិធីអនុវត្តដោយបង្ខំ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 570 )
- ⇒ខ្លឹមសារលម្អិតគឺ ?

# ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

- អាជ្ញាសាលាដកហូតនូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុល ហើយធ្វើការថែរក្សាគ្រប់គ្រង (បន្ថែមពីនេះ អនុញ្ញាតឲ្យកូនបំណុល ឬ ម្ចាស់បំណុលប្រើប្រាស់នូវវត្ថុដែលជាកម្មវត្ថុ អាស្រ័យទៅតាមខ្លឹមសារនៃដីកាសម្រេច) ព្រមទាំងប្រកាសជាសាធារណៈអំពីការហាមឃាត់នូវការផ្ទេរការកាន់កាប់របស់កូនបំណុល និង ការថែរក្សាគ្រប់គ្រងដោយអាជ្ញាសាលាលើវត្ថុនោះ (យោងក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 571 កថា.ទី1)។

⇒វិធីសាស្ត្រលម្អិតនៃប្រកាសជាសាធារណៈមាន?

បញ្ឈរសន្លឹកក្រដាស ឬ បិទភ្ជាប់នឹងអាគារដើម្បីកុំឲ្យលិខិតប្រកាសហើរបាត់ ជាដើម។

# ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុ

- អាស្រ័យតាមការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ (ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា36)។ ក្រឡាបញ្ជីផ្ទុកផ្តាក់នូវការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន(ប្រកាសដដែល មាត្រា20)
- សមត្ថកិច្ច គឺ តុលាការដែលចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។
- អានុភាពនៃការអនុវត្តនឹងកើតមានឡើងនៅពេលដែលបានចុះបញ្ជី។

# ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ម៉ាន:ជាបណ្ដោះអាសន្ន

- អនុវត្តដូចគ្នានឹងវិធីអនុវត្តលើការរឹបអូសជាបណ្ដោះអាសន្ន ឬ តាមការអនុវត្តដោយបង្ខំដោយផ្ទាល់ ឬ តាមវិធានបង្ខំដោយប្រយោល ឬ តាមការអនុវត្តជំនួស អាស្រ័យទៅតាមខ្លឹមសារនៃការចាត់ចែងជាបណ្ដោះអាសន្ននោះ។

# ការធ្វើឧបាស្រ័យចំពោះការអនុវត្តរក្សាការពារ

ការតវ៉ាចំពោះការអនុវត្ត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា344) ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្តជាអាទិ៍ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា362) បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា364) បណ្តឹងតវ៉ារបស់តតិយជន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 365) ជាអាទិ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ។